# ពិធីផ្សព្វផ្សាយ
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣
# នៅថ្នាក់ក្រោមជាតិ

# ដំណើរការរៀបចំ និង ទម្រង់ របស់
# ឯកសារ ផ.យ.អ.ជ. ២០១៩-២០២៣

អគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ

*ខេត្តតាកែវ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០*
*ខេត្តសៀមរាប ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០*
*ខេត្តក្រចេះ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០*

# មាតិកា

១. គោលបំណងនៃការរៀបចំ *ផ.យ.អ.ជ. ២០១៩-២០២៣*

២. ដំណើរការនៃការរៀបចំ *ផ.យ.អ.ជ. ២០១៩-២០២៣*

៣. ទម្រង់នៃ ផ.យ.អ.ជ. ២០១៩-២០២៣

# ១. គោលបំណងនៃការរៀបចំ ផ.យ.អ.ជ. ២០១៩-២០២៣

ផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានរៀបចំឡើងដើម្បីសម្រេចគោលដៅចម្បង ចំនួន ៣ គឺ៖

- ទី១៖ ដើម្បីវាយតម្លៃអំពីលទ្ធផលរួមនិងបញ្ហាប្រឈមចម្បងៗ ដែលបានកើតមានឡើងនៅក្នុងការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨* ក្នុងអាណត្តិកាលរបស់ផែនការនេះទាំងមូល ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨
- ទី២៖ ដើម្បីកំណត់នូវបណ្តាវិធានការគោលនយោបាយនានា ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ សម្រាប់ការអនុវត្តគោលនយោបាយអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា និង បណ្តារបៀបវារៈសាកល អនុសញ្ញា និងកម្មវិធីអន្តរជាតិនានា នៅតាមវិស័យ និង
- ទី៣៖ ដើម្បីដាក់ចេញនូវប្រព័ន្ធមួយ សម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ នូវការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*។

## ២. ដំណើរការនៃការរៀបចំ ផ.យ.អ.ជ. ២០១៩-២០២៣

- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ថ្ងៃទី២ ខែមករា ឆ្នាំ២០១៨ ផ្តល់សិទ្ធិប្រទានដល់ក្រសួងផែនការ ក្នុងការដឹកនាំ សម្របសម្រួលការរៀបចំ *ផ.យ.អ.ជ. ២០១៩-២០២៣*។
- រៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីណែនាំដល់ក្រសួង ស្ថាប័ន ពីការរៀបចំធាតុចូលដល់ ក្រសួងផែនការ សម្រាប់រៀបចំ *ផ.យ.អ.ជ. ២០១៩-២០២៣* (១៦ ឧសភា ២០១៨)។
- រៀបចំសេចក្តីព្រាង *ផ.យ.អ.ជ. ២០១៩-២០២៣* ដោយផ្អែកលើ ធាតុចូលពីក្រសួង ស្ថាប័ននិងភាគីដែលមានចំណែកពាក់ព័ន្ធ គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ព័ត៌មាននិងទិន្នន័យថ្មីៗ និង បញ្ជ្រាប បណ្តារបៀបវារៈសាកល អនុសញ្ញា និងកម្មវិធី អន្តរជាតិនានា ដែលត្រូវចូលរួមអនុវត្ត។
- ពិភាក្សា សេចក្តីព្រាង *ផ.យ.អ.ជ. ២០១៩-២០២៣* ក្នុងកិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេស (២៨-២៩ វិច្ឆិកា ២០១៨)។
- ក្រុមការងារជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ជួបប្រជុំពិភាក្សាដើម្បីពិភាក្សារៀបចំសូចនាករស្នូល សម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (២៤-២៥ ធ្នូ ២០១៨)។

# ២. ដំណើរការនៃការរៀបចំ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

- ជួបប្រជុំជាមួយពិភាក្សាជាមួយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ដើម្បីពិនិត្យមើល ទំនាក់ទំនងរវាង ធាតុចូលរបស់ ក្រសួង ស្ថាប័ន ជាមួយនឹង ថវិកាកម្មវិធី (១៤ មករា ២០១៩)។
- ជួបប្រជុំក្រុមការងារជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីពិភាក្សាលើបញ្ជីសូចនាករស្នូល សម្រាប់ តាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ. ២០១៩-២០២៣ (២៤-២៥ មករា ២០១៩)។
- ពិភាក្សាសេចក្តីព្រាងកែសម្រួល *ផ.យ.អ.ជ. ២០១៩-២០២៣* ក្នុងកិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេស (២៨ មករា ២០១៩)។
- ពិនិត្យនិងផ្តល់ការឯកភាពលើ សេចក្តីព្រាង ផ.យ.អ.ជ. ២០១៩-២០២៣ ក្នុងកិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយ (២២ កុម្ភៈ ២០១៩)។
- សេចក្តីព្រាង *ផ.យ.អ.ជ. ២០១៩-២០២៣* ត្រូវបានពិនិត្យនិងផ្តល់ការណែនាំ ជាគោលការណ៍ នៅក្នុងកិច្ចប្រជុំ គណៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (២ មេសា ២០១៩)។

# ២. ដំណើរការនៃការរៀបចំ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

- សេចក្តីព្រាង *ផ.យ.អ.ជ. ២០១៩-២០២៣* ត្រូវបានទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី (៧ មិថុនា ២០១៩)។
- ឯកសារ *ផ.យ.អ.ជ. ២០១៩-២០២៣* ត្រូវបានទទួលបានការអនុម័តពីរដ្ឋសភា (១ កក្កដា ២០១៩)។
- ឯកសារ *ផ.យ.អ.ជ. ២០១៩-២០២៣* ត្រូវបានទទួលបានការអនុម័តពីព្រឹទ្ធសភា (១១ កក្កដា ២០១៩)។
- ផ្សព្វផ្សាយថ្នាក់ជាតិ ថ្ងៃទី៧ វិច្ឆិកា ឆ្នាំ២០១៩។

# ៣. ទម្រង់នៃ ផ.យ.អ.ជ. ២០១៩-២០២៣

*ផ.យ.អ.ជ. ២០១៩-២០២៣* ចែកចេញជា ៧ជំពូក៖

- ជំពូកទី១៖ ទិដ្ឋភាពរួមនៃការវិវត្តនិងភាពជោគជ័យក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។
- ជំពូកទី២៖ សមិទ្ធផលនិងបញ្ហាប្រឈមនានា ដែលជួបប្រទះ នៅក្នុងពេលអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨។
- ជំពូកទី៣៖ ស្ថានភាពរួមនៃម៉ាក្រូសេដ្ឋកិច្ច និងទិសដៅសម្រាប់៥ឆ្នាំបន្ទាប់ *(លទ្ធភាពថវិកាសម្រាប់អនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣)*។

# ៣. ទម្រង់នៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

- **ជំពូកទី៤៖** គោលនយោបាយអាទិភាពសំខាន់ៗ និង សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ។ ចែកចេញជា២ផ្នែក៖
  - **ផ្នែកទី១៖** គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៦ ដកស្រង់ចេញពីយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤។
  - **ផ្នែកទី២៖** សកម្មភាព កម្មវិធី និងគម្រោង សម្រាប់អនុវត្តគោលនយោបាយអាទិភាព ចែងក្នុងផ្នែកទី១។
- **ជំពូកទី៥៖** ការកំណត់តម្រូវការធនធាន និងកម្មវិធីចំណាយសម្រាប់អនុវត្តសកម្មភាព កម្មវិធី និងគម្រោង ដែលបានលើកឡើង ក្នុងជំពូកទី៤។
- **ជំពូកទី៦៖**យន្តការសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ. ២០១៩-២០២៣
- **ជំពូកទី៧៖** សេចក្តីសន្និដ្ឋានរួម។

# សូមអរគុណ !